**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៣៤ សហវ.ប្រក.

# ប្រកាស

# ស្តីពី

# ពន្ធលើប្រតិបត្តិការប្រេងកាត

## ឧបនាយករដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច

**ប្រការ១ .-**

ប្រកាសនេះ មានគោលបំណងកំណត់នូវវិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធលើប្រតិបត្តិការប្រេងកាត។

**ប្រការ២ .-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការប្រេងកាត នៅក្នុងបូរណភាពទឹកដីនិងអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងតំបន់ផ្សេងៗទៀតដែលព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិអធិបតេយ្យ។

**ប្រការ៣ .-**

សម្រាប់គោលដៅនៃប្រកាសនេះ៖

១- ប្រេងកាត សំដៅដល់ ប្រេងឆៅ ឧស្ម័នធម្មជាតិ និងអ៊ីដ្រូកាបួផ្សេងទៀត ទោះបីជាស្ថិតក្នុងសភាពរឹង រាវ ឧស្ម័ន ស្ថានភាពធម្មជាតិ និងរាល់សារធាតុផ្សេងទៀតដែលជាសមាសធាតុផ្សំជាមួយអ៊ីដ្រូកាបួនោះ។

២-កិច្ចព្រមព្រៀងប្រេងកាត សំដៅដល់ កិច្ចសន្យាបែងចែកផលប្រេងកាត ឬទម្រង់កិច្ចសន្យាណាមួយដែលត្រូវបានផ្តល់ឱ្យក្រោមច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត និងបទប្បញ្ញត្តិពាក់ព័ន្ធរវាងរាជរដ្ឋាភិបាលកម្ពុជានិងអ្នកជាប់ពន្ធពាក់ព័ន្ធ ដើម្បីធ្វើប្រតិបត្តិការប្រេងកាត។

៣-ប្រតិបត្តិការប្រេងកាត សំដៅដល់ រាល់សកម្មភាពស្វែងរុករក អភិវឌ្ឍ និងផលិតប្រេងកាត ដែលបានធ្វើឡើងនៅក្នុងតំបន់ចុះកិច្ចព្រមព្រៀងប្រេងកាត ស្របតាមកិច្ចព្រមព្រៀងប្រេងកាត។

៤-តំបន់ចុះកិច្ចព្រមព្រៀង សំដៅដល់ តំបន់ដែលជាកម្មវត្ថុនៃកិច្ចព្រមព្រៀងប្រេងកាត ដែលបានអនុញ្ញាតផ្តល់ឱ្យពីដំបូង រួមបញ្ចូលទាំងផ្នែកណាមួយនៃតំបន់នោះដែលត្រូវបានប្រគល់សងវិញ ដោយអនុលោមទៅតាមកិច្ចព្រមព្រៀងប្រេងកាត។

៥- គម្រោងអភិវឌ្ឍន៍ សំដៅដល់ ផែនការអភិវឌ្ឍន៍ កម្មវិធីការងារអភិវឌ្ឍន៍ និងសកម្មភាពការងារអភិវឌ្ឍន៍នានាដើម្បីអភិវឌ្ឍនិងធ្វើផលិតកម្មប្រេងកាតនៅក្នុងតំបន់ចុះកិច្ចព្រមព្រៀងដែលបានយល់ព្រមដោយស្ថាប័ន។

៦- ផែនការបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ សំដៅដល់ ផែនការបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញរបស់អ្នកជាប់ពន្ធដែលបានយល់ព្រមដោយស្ថាប័នក្រោមកិច្ចព្រមព្រៀងប្រេងកាត ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាតនិងផលិតផលប្រេងកាត។

៧-ចំណាយបុរេសនា សំដៅដល់ ចំណាយក្នុងការស្វែងរុករកដើម្បីកំណត់សក្តានុពលភូគព្ភសាស្ត្រប្រេងកាតដំហានដំបូងដោយមិនមានសិទ្ធិធ្វើការអភិវឌ្ឍនិងផលិតកម្ម។

៨- ចំណាយស្វែងរុករក សំដៅដល់ ចំណាយក្នុងការអង្កេតផ្នែកភូគព្ភសាស្ត្រ សិលាវិទ្យា រូបភូគព្ភសាស្ត្រ គីមីភូគព្ភសាស្ត្រ ឋានលេខា ចំណាយវិភាគទិន្នន័យ ចំណាយទស្សនាទានវិស្វកម្មមុនពេលអភិវឌ្ឍន៍ ចំណាយលើការខួងស្វែងរុករក ខួងវាយតម្លៃ ការសិក្សាលើសមិទ្ធិលទ្ធភាព ផលប៉ះពាល់បរិស្ថាន ចំណាយរដ្ឋបាលទូទៅ និងចំណាយផ្សេងៗទៀតដែលកើតឡើងនៅក្នុងប្រតិបត្តិការប្រេងកាត ដើម្បីកំណត់វត្តមាន ទីតាំង បរិមាណ និងគុណភាពនៃជម្រកធនធានប្រេងកាត។

៩-ចំណាយអភិវឌ្ឍន៍ សំដៅដល់ ចំណាយដែលបានកើតឡើងបន្ទាប់ពីស្ថាប័នបានយល់ព្រមចំពោះគម្រោងអភិវឌ្ឍន៍ ដើម្បីសាងសង់មធ្យោបាយផលិតកម្មសម្រាប់ប្រតិបត្តិការប្រេងកាត មានជាអាទិ៍ ការរៀបចំទីតាំង ការខួងអណ្តូង ការសាងសង់អណ្តូងសម្រាប់ផលិតកម្ម និងការសាងសង់បំពង់បង្ហូរប្រេងកាតដែលជាមធ្យោបាយផលិតកម្ម ការចំណាយលើការទិញទ្រព្យរូបីនិងទ្រព្យអរូបី ព្រមទាំងសកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងការអភិវឌ្ឍរបស់អ្នកចុះកិច្ចព្រមព្រៀងប្រេងកាត ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងលិខិតអនុញ្ញាតផលិតកម្មចេញដោយស្ថាប័ន។

១០-ប្រាក់បម្រុងសម្រាប់ចំណាយបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ សំដៅដល់ ប្រាក់បម្រុងដែលត្រូវបានអនុញ្ញាតឱ្យកាត់កងជាមុនសម្រាប់ចំណាយបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញស្របតាមផែនការនិងលក្ខខណ្ឌកំណត់ដោយស្ថាប័ន។



ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

១១-ចំណាយសរុបសម្រាប់បិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ សំដៅដល់ ចំណាយសរុបសម្រាប់បិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញនៅក្នុងតំបន់ចុះកិច្ចព្រមព្រៀងដែលបានយល់ព្រមដោយស្ថាប័នតាមគម្រោងបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញរបស់អ្នកជាប់ពន្ធស្របតាមកិច្ចព្រមព្រៀងប្រេងកាត។

១២-ពេលចាប់ផ្តើមផលិតកម្មពាណិជ្ជកម្ម សំដៅដល់ ពេលដែលអ្នកជាប់ពន្ធចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មស្របតាមការកំណត់ក្នុងកិច្ចព្រមព្រៀងប្រេងកាតឬការកំណត់ដោយស្ថាប័ន។

១៣-បំណុល សំដៅដល់ ចំនួនទឹកប្រាក់សរុបដែលអ្នកជាប់ពន្ធជំពាក់ឬត្រូវបង់សង រួមទាំងប្រាក់ខ្ចី ឧបករណ៍ហិរញ្ញវត្ថុ កតិសន្យាហិរញ្ញវត្ថុ ឬឧបករណ៍ហិរញ្ញវត្ថុណាមួយដែលបង្កើតជាការប្រាក់ ការបញ្ចុះតម្លៃ និងបន្ទុកហិរញ្ញវត្ថុដទៃទៀត ដែលអាចកាត់កងបានដើម្បីគណនាប្រាក់ចំណូលជាប់ពន្ធ។

១៤-ដើមទុន រួមមាន មូលធនភាគហ៊ុនគ្រប់ប្រភេទ តម្លៃលើសនៃការលក់បណ្ណភាគហ៊ុន មូលធនបម្រុងតាមច្បាប់ លម្អៀងលើសនៃការវាយតម្លៃឡើងវិញនូវទ្រព្យសកម្ម និងប្រាក់ចំណូលរក្សាទុក។

១៥-អ្នកជាប់ពន្ធ សំដៅដល់ រូបវន្តបុគ្គលឬនីតិបុគ្គលដែលបានចុះកិច្ចព្រមព្រៀងប្រេងកាតជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា។

១៦-ស្ថាប័ន សំដៅដល់ ក្រសួងរ៉ែនិងថាមពល ឬស្ថាប័នរាជរដ្ឋាភិបាលដែលទទួលបន្ទុកគ្រប់គ្រងវិស័យប្រេងកាត។

**ប្រការ៤ .-**

១- អនុលោមតាមមាត្រា១២៧ នៃច្បាប់ស្តីពីសារពើពន្ធ៖

ក- អ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការប្រេងកាត ដូចមានចែងក្នុងប្រការ៣ នៃប្រកាសនេះ ត្រូវជាប់ពន្ធលើប្រាក់ចំណូលតាមអត្រា ៣០ (សាមសិប) ភាគរយ នៃប្រាក់ចំណូលជាប់ពន្ធក្នុងឆ្នាំជាប់ពន្ធ។

ខ- បន្ថែមលើអត្រាពន្ធដូចមានចែងក្នុងវាក្យខណ្ឌ ក នៃកថាខណ្ឌនេះ ប្រសិនបើអ្នកជាប់ពន្ធមានប្រាក់ចំណូលលើសកម្រិត អ្នកជាប់ពន្ធត្រូវជាប់ពន្ធលើប្រាក់ចំណូលលើសកម្រិត តាមអត្រាកំណើនតាមថ្នាក់ដោយផ្អែកលើសមាមាត្រនៃប្រាក់ចំណូលលើសកម្រិតដូចក្នុងតារាងខាងក្រោម៖

| ថ្នាក់ | សមាមាត្រនៃប្រាក់ចំណូលលើសកម្រិត | អត្រាពន្ធលើប្រាក់ចំណូលលើសកម្រិត |
|---|---|---|
| ១ | ដល់ ១,៣ | 0% |
| ២ | លើសពី ១,៣ ដល់ ១,៦ | ១0% |
| ៣ | លើសពី ១,៦ ដល់ ២ | ២0% |
| ៤ | លើសពី ២ ឡើងទៅ | ៣0% |

២- សមាមាត្រនៃប្រាក់ចំណូលលើសកម្រិតនៃឆ្នាំជាប់ពន្ធចរន្តណាមួយ គឺជាផលចែកនៃទឹកប្រាក់បូកបង្គរនៃចំណូល នឹងទឹកប្រាក់បូកបង្គរនៃចំណាយ ពីប្រតិបត្តិការប្រេងកាតមកទល់នឹងឆ្នាំជាប់ពន្ធចរន្តនោះ។

៣- ការគណនាពន្ធលើប្រាក់ចំណូលលើសកម្រិត ត្រូវអនុវត្តតាមជំហានដូចខាងក្រោម៖

ក- គណនារកមូលដ្ឋានគិតពន្ធលើប្រាក់ចំណូលលើសកម្រិតតាមថ្នាក់នីមួយៗ ដោយយកប្រាក់ចំណូលជាប់ពន្ធក្នុងឆ្នាំចរន្ត គុណនឹងផលចែកនៃលម្អៀងសមាមាត្រនៃប្រាក់ចំណូលលើសកម្រិតតាមថ្នាក់នីមួយៗ នឹងសមាមាត្រនៃប្រាក់ចំណូលលើសកម្រិតតាមថ្នាក់នីមួយៗ។

ខ- គណនាពន្ធលើប្រាក់ចំណូលលើសកម្រិតតាមថ្នាក់នីមួយៗ ដោយយកមូលដ្ឋានគិតពន្ធលើប្រាក់ចំណូលលើសកម្រិតតាមថ្នាក់នីមួយៗដែលបានគណនាតាមវាក្យខណ្ឌ ក នៃកថាខណ្ឌនេះ គុណនឹងអត្រាពន្ធសម្រាប់ថ្នាក់នោះ។

គ- បូកសរុបប្រាក់ពន្ធលើប្រាក់ចំណូលលើសកម្រិតនៃថ្នាក់នីមួយៗ។

**ឧទាហរណ៍ទី១៖** អ្នកជាប់ពន្ធ មានស្ថានភាពចំណូលចំណាយ ដែលគណនាជាសមាមាត្រនៃប្រាក់ចំណូលលើសកម្រិត (សចលក.) ដូចខាងក្រោម៖

| ឆ្នាំជាប់ពន្ធ | ចំណូល | | ចំណាយ | | ចំណូលសុទ្ធ | សចលក. |
|---|---|---|---|---|---|---|
| | ក្នុងឆ្នាំ | បង្គរ | ក្នុងឆ្នាំ | បង្គរ | | |
| | (ក) | (ខ) | (គ) | (ឃ) | (ង)=(ក)-(គ) | (ច)=(ខ)/(ឃ) |
| ២០១៧ | ១០០ ០០០ ០០០ | ១០០ ០០០ ០០០ | ៨០ ០០០ ០០០ | ៨០ ០០០ ០០០ | ២០ ០០០ ០០០ | ១,២៥ |
| ២០១៨ | ១៣០ ០០០ ០០០ | ២៣០ ០០០ ០០០ | ៩០ ០០០ ០០០ | ១៧០ ០០០ ០០០ | ៤០ ០០០ ០០០ | ១,៣៥ |
| ២០១៩ | ១៥០ ០០០ ០០០ | ៣៨០ ០០០ ០០០ | ១០០ ០០០ ០០០ | ២៧០ ០០០ ០០០ | ៥០ ០០០ ០០០ | ១,៤១ |
| ២០២០ | ២០០ ០០០ ០០០ | ៥៨០ ០០០ ០០០ | ១២០ ០០០ ០០០ | ៣៩០ ០០០ ០០០ | ៨០ ០០០ ០០០ | ១,៤៩ |
| ២០២១ | ២១០ ០០០ ០០០ | ៧៩០ ០០០ ០០០ | ១៣០ ០០០ ០០០ | ៥២០ ០០០ ០០០ | ៨០ ០០០ ០០០ | ១,៥២ |
| ២០២២ | ២៣០ ០០០ ០០០ | ១ ០២០ ០០០ ០០០ | ១០០ ០០០ ០០០ | ៦២០ ០០០ ០០០ | ១៣០ ០០០ ០០០ | ១,៦៥ |
| ២០២៣ | ២៥០ ០០០ ០០០ | ១ ២៧០ ០០០ ០០០ | ១១០ ០០០ ០០០ | ៧៣០ ០០០ ០០០ | ១៤០ ០០០ ០០០ | ១,៧៤ |
| ២០២៤ | ៣០០ ០០០ ០០០ | ១ ៥៧០ ០០០ ០០០ | ១០០ ០០០ ០០០ | ៨៣០ ០០០ ០០០ | ២០០ ០០០ ០០០ | ១,៨៩ |
| ២០២៥ | ៥០០ ០០០ ០០០ | ២ ០៧០ ០០០ ០០០ | ១៣០ ០០០ ០០០ | ៩៦០ ០០០ ០០០ | ៣៧០ ០០០ ០០០ | ២,១៦ |
| ២០២៦ | ៦០០ ០០០ ០០០ | ២ ៦៧០ ០០០ ០០០ | ១៥០ ០០០ ០០០ | ១ ១១០ ០០០ ០០០ | ៤៥០ ០០០ ០០០ | ២,៤១ |

**ការគណនាពន្ធលើប្រាក់ចំណូល និងពន្ធលើប្រាក់ចំណូលលើសកម្រិត (ពចលក.)៖**

**១- ឆ្នាំជាប់ពន្ធ ២០១៧៖**

អ្នកជាប់ពន្ធមានចំណូល ១០០ ០០០ ០០០ រៀល និងចំណាយ ៨០ ០០០ ០០០ រៀល និងសមាមាត្រនៃប្រាក់ចំណូលលើសកម្រិតស្មើនឹង ១,២៥។ ដូចនេះ ប្រាក់ចំណូលជាប់ពន្ធគឺ ២០ ០០០ ០០០ រៀល ត្រូវជាប់ពន្ធលើប្រាក់ចំណូល និងពន្ធលើប្រាក់ចំណូលលើសកម្រិតតាមអត្រា ០%។

**ពន្ធលើប្រាក់ចំណូលត្រូវបង់សរុប = ពន្ធលើប្រាក់ចំណូល + ពន្ធលើប្រាក់ចំណូលលើសកម្រិត**

= (២០ ០០០ ០០០ x ៣០%) + 0

= **៦ ០០០ ០០០ រៀល**

**២- ឆ្នាំជាប់ពន្ធ ២០១៨៖**

អ្នកជាប់ពន្ធមានចំណូលបង្គរ ២៣០ ០០០ ០០០ រៀល និងចំណាយបង្គរ ១៧០ ០០០ ០០០ រៀល និងសមាមាត្រនៃប្រាក់ចំណូលលើសកម្រិតស្មើនឹង ១,៣៥។ ដូចនេះ ប្រាក់ចំណូលជាប់ពន្ធគឺ ៤០ ០០០ ០០០ រៀល ត្រូវជាប់ពន្ធលើប្រាក់ចំណូល និងពន្ធលើប្រាក់ចំណូលលើសកម្រិតតាមអត្រា ១០%។

មូលដ្ឋានគិត **ពចលក.** តាមអត្រា ១០% = ៤០ ០០០ ០០០ x ( (១,៣៥ – ១,៣) / ១,៣៥ )

= ១ ៤៨១ ៤៨១ រៀល

**ពចលក.** តាមអត្រា ១០% = មូលដ្ឋានគិត ពចលក. x អត្រា ពចលក. ១០%

= ១ ៤៨១ ៤៨១ x ១០%

= ១៤៨ ១៤៨ រៀល

**ពន្ធលើប្រាក់ចំណូលត្រូវបង់សរុប = ពន្ធលើប្រាក់ចំណូល + ពន្ធលើប្រាក់ចំណូលលើសកម្រិត**

= (៤០ ០០០ ០០០ x ៣០%) + ១៤៨ ១៤៨

= **១២ ១៤៨ ១៤៨ រៀល**

**៣- ឆ្នាំជាប់ពន្ធ ២០២២៖**

អ្នកជាប់ពន្ធមានចំណូលបង្គរ ១ ០២០ ០០០ ០០០ រៀល និងចំណាយបង្គរ ៦២០ ០០០ ០០០ រៀល និងសមាមាត្រនៃប្រាក់ចំណូលលើសកម្រិតស្មើនឹង ១,៦៥។ ដូចនេះ ប្រាក់ចំណូលជាប់ពន្ធគឺ ១៣០ ០០០ ០០០ រៀល ត្រូវជាប់ពន្ធលើប្រាក់ចំណូល និងពន្ធលើប្រាក់ចំណូលលើសកម្រិតតាមអត្រា ១០% ផង និងអត្រា ២០% ផង។

មូលដ្ឋានគិត **ពចលក.** តាមអត្រា ១០% = ១៣០ ០០០ ០០០ x ( (១,៦ – ១,៣) / ១,៦ )

= ២៤ ៣៧៥ ០០០ រៀល

**ពចលក.** តាមអត្រា ១០% = មូលដ្ឋានគិត ពចលក. x អត្រា ពចលក. ១០%
= ២៤ ៣៧៥ ០០០ x ១០%
= ២ ៤៣៧ ៥០០ រៀល

មូលដ្ឋានគិត **ពចលក.** តាមអត្រា ២០% = ១៣០ ០០០ ០០០ x $\left(\frac{១,៦៥ - ១,៦}{១,៦៥}\right)$
= ៣ ៩៣៩ ៣៩៤ រៀល

**ពចលក.** តាមអត្រា ២០% = មូលដ្ឋានគិត ពចលក. x អត្រា ពចលក. ២០%
= ៣ ៩៣៩ ៣៩៤ x ២០%
= ៧៨៧ ៨៧៩ រៀល

**ពន្ធលើប្រាក់ចំណូលត្រូវបង់សរុប = ពន្ធលើប្រាក់ចំណូល + ពន្ធលើប្រាក់ចំណូលលើសកម្រិត**
= (១៣០ ០០០ ០០០ x ៣០%) + (២ ៤៣៧ ៥០០ + ៧៨៧ ៨៧៩)
= **៤២ ២២៥ ៣៧៩ រៀល**

**៤- ឆ្នាំជាប់ពន្ធ ២០២៥៖**

អ្នកជាប់ពន្ធមានចំណូលបង្គរ ២ ០៧០ ០០០ ០០០ រៀល និងចំណាយបង្គរ ៩៦០ ០០០ ០០០ រៀល និងសមាមាត្រនៃប្រាក់ចំណូលលើសកម្រិតស្មើនឹង ២,១៦។ ដូចនេះ ប្រាក់ចំណូលជាប់ពន្ធគឺ ៣៧០ ០០០ ០០០ រៀល ត្រូវជាប់ពន្ធលើប្រាក់ចំណូលនិងពន្ធលើប្រាក់ចំណូលលើសកម្រិតតាមអត្រា១០%ផង អត្រា២០%ផង និងអត្រា ៣០%ផង។

មូលដ្ឋានគិត **ពចលក.** តាមអត្រា ១០% = ៣៧០ ០០០ ០០០ x $\left(\frac{១,៦ - ១,៣}{១,៦}\right)$
= ៦៩ ៣៧៥ ០០០ រៀល

**ពចលក.** តាមអត្រា ១០% = មូលដ្ឋានគិត ពចលក. x អត្រា ពចលក. ១០%
= ៦៩ ៣៧៥ ០០០ x ១០%
= ៦ ៩៣៧ ៥០០ រៀល

មូលដ្ឋានគិត **ពចលក.** តាមអត្រា ២០% = ៣៧០ ០០០ ០០០ x $\left(\frac{២ - ១,៦}{២}\right)$
= ៧៤ ០០០ ០០០ រៀល

**ពចលក.** តាមអត្រា ២០% = មូលដ្ឋានគិត ពចលក. x អត្រា ពចលក. ២០%
= ៧៤ ០០០ ០០០ x ២០%
= ១៤ ៨០០ ០០០ រៀល

មូលដ្ឋានគិត **ពចលក.** តាមអត្រា ៣០% = ៣៧០ ០០០ ០០០ x $\left(\frac{២,១៦ - ២}{២,១៦}\right)$
= ២៧ ៤០៧ ៤០៧ រៀល

**ពចលក.** តាមអត្រា ៣០% = មូលដ្ឋានគិត ពចលក. x អត្រា ពចលក. ៣០%
= ២៧ ៤០៧ ៤០៧ x ៣០%
= ៨ ២២២ ២២២ រៀល

**ពន្ធលើប្រាក់ចំណូលត្រូវបង់សរុប = ពន្ធលើប្រាក់ចំណូល + ពន្ធលើប្រាក់ចំណូលលើសកម្រិត**
= (៣៧០ ០០០ ០០០ x ៣០%) + (៦ ៩៣៧ ៥០០ + ១៤ ៨០០ ០០០ + ៨ ២២២ ២២២)
= **១៤០ ៩៥៩ ៧២២ រៀល**

**ប្រការ៥ .-**

អ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការប្រេងកាត ត្រូវបានអនុញ្ញាតឱ្យកាត់កងចំណាយការប្រាក់ត្រឹមតែចំនួនដែលគណនាតាមវិធានសមាមាត្រនៃបំណុល ៣ (បី) ធៀបនឹង ដើមទុន ១ (មួយ) ទោះបីអ្នកជាប់ពន្ធខ្ចីបុលប្រាក់ដើម្បីប្រកបអាជីវកម្មរបស់ខ្លួនក្នុងកម្រិតណាក៏ដោយ។

**ឧទាហរណ៍ទី២៖** អ្នកជាប់ពន្ធ ក ធ្វើប្រតិបត្តិការប្រេងកាតនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានដើមទុនចំនួន ១០០ ០០០ ០០០ រៀល។ ដោយខ្វះដើមទុន អ្នកជាប់ពន្ធបានខ្ចីប្រាក់ចំនួន ៥០០ ០០០ ០០០ រៀល ក្នុងអត្រាការប្រាក់ ៥% ក្នុងមួយឆ្នាំ។ ដូចនេះ ចំណាយការប្រាក់ដែលអ្នកជាប់ពន្ធ ក ត្រូវបង់ឱ្យម្ចាស់បំណុលក្នុងមួយឆ្នាំស្មើនឹង ៥០០ ០០០ ០០០ x ៥% = ២៥ ០០០ ០០០ រៀល។

ក្នុងការគណនាប្រាក់ចំណូលជាប់ពន្ធ អ្នកជាប់ពន្ធ ក មិនអាចកាត់កងចំណាយការប្រាក់ដែលបង់ឱ្យម្ចាស់បំណុលទាំងស្រុងចំនួន ២៥ ០០០ ០០០ រៀល បានទេ។ អ្នកជាប់ពន្ធត្រូវគណនាការប្រាក់ដែលអនុញ្ញាតឱ្យកាត់កងតាមវិធានសមាមាត្របំណុល ៣ ធៀបនឹងដើមទុន ១ ដូចខាងក្រោម៖

| | | |
|---|---|---|
| មូលដ្ឋានគិតការប្រាក់ដើម្បីកាត់កង | = | ដើមទុនរបស់អ្នកជាប់ពន្ធ x ៣ |
| | = | ១០០ ០០០ ០០០ x ៣ |
| | = | ៣០០ ០០០ ០០០ រៀល |
| ចំនួនការប្រាក់ដែលអនុញ្ញាតឱ្យកាត់កង | = | មូលដ្ឋានគិតការប្រាក់ដើម្បីកាត់កង x អត្រាការប្រាក់ |
| | = | ៣០០ ០០០ ០០០ x ៥% |
| | = | **១៥ ០០០ ០០០ រៀល** |

ដោយឡែកចំពោះពន្ធកាត់ទុកដែលមានចែងក្នុងមាត្រា២៥ ឬមាត្រា២៦ នៃច្បាប់ស្តីពីសារពើពន្ធ ត្រូវអនុវត្តលើចំណាយការប្រាក់ជាក់ស្តែងចំនួន ២៥ ០០០ ០០០ រៀល ដែលបានបង់ឱ្យម្ចាស់បំណុល។

## ប្រការ៦ ._

ប្រាក់បម្រុងសម្រាប់ចំណាយបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ ដូចមានចែងក្នុងមាត្រា១៣០ នៃច្បាប់ស្តីពីសារពើពន្ធ ត្រូវបានកំណត់ដូចខាងក្រោម៖

១- ប្រសិនបើអ្នកជាប់ពន្ធមានផែនការបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញដែលបានយល់ព្រមដោយស្ថាប័ន ទឹកប្រាក់ដែលបានតម្រូវឱ្យអ្នកជាប់ពន្ធបង់ចូលមូលនិធិសម្រាប់ចំណាយបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ ត្រូវបានចាត់ទុកជាប្រាក់បម្រុងសម្រាប់ចំណាយបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ។ ប្រាក់បម្រុងនេះ ត្រូវបានអនុញ្ញាតជាសំវិធានធន និងត្រូវបានអនុញ្ញាតឱ្យកាត់កងក្នុងឆ្នាំជាប់ពន្ធ ដើម្បីគណនាប្រាក់ចំណូលជាប់ពន្ធ។ ក្នុងករណីអ្នកជាប់ពន្ធគ្មានផែនការបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញដែលបានយល់ព្រមដោយស្ថាប័នទេ ប្រាក់បម្រុងតាមកថាខណ្ឌនេះមិនត្រូវបានអនុញ្ញាតឡើយ។

២- ប្រាក់បម្រុងសម្រាប់ចំណាយបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ ត្រូវបានគណនាដោយផ្អែកទៅតាមចំណាយសរុបដែលបានយល់ព្រមដោយស្ថាប័នសម្រាប់បិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ។ ប្រាក់បម្រុងសម្រាប់ចំណាយបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញក្នុងឆ្នាំនីមួយៗ និងឆ្នាំដែលប្រាក់បម្រុងត្រូវបានអនុញ្ញាតឱ្យចាប់ផ្តើមកាត់កង ត្រូវកំណត់តាមផែនការបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ។

៣-ប្រសិនបើចំណាយសរុបជាក់ស្តែងនៃការបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ មានចំនួនលើសពីចំនួនសរុបនៃទឹកប្រាក់បម្រុងសម្រាប់ចំណាយបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ ចំនួនលើសនោះត្រូវបានអនុញ្ញាតឱ្យកាត់កងពីប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ។

**ឧទាហរណ៍ទី៣៖** អ្នកជាប់ពន្ធ ក ធ្វើប្រតិបត្តិការប្រេងកាតក្នុងតំបន់ចុះកិច្ចព្រមព្រៀងមួយ ដែលមានអាយុកាលរំពឹងទុកនៃផលិតកម្មចំនួន ៥ឆ្នាំ។ ទឹកប្រាក់បម្រុងសម្រាប់បិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញដែលបានយល់ព្រមដោយស្ថាប័នមានចំនួន ៤០០ ០០០ រៀល។ ចំនួនទឹកប្រាក់បម្រុងសម្រាប់បិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញនេះ ត្រូវបានអនុញ្ញាតឱ្យកាត់កងចាប់ពីឆ្នាំជាប់ពន្ធទី១ រហូតដល់ឆ្នាំជាប់ពន្ធទី៥ ដោយក្នុងមួយឆ្នាំៗមានចំនួន ៨០ ០០០ រៀល។ ក្នុងការបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញជាក់ស្តែង អ្នកជាប់ពន្ធ ក បានចំណាយទឹកប្រាក់សរុបចំនួន ៤១០ ០០០ រៀល ដែលលើសពីទឹកប្រាក់បម្រុងចំនួន ១០ ០០០ រៀល។ ទឹកប្រាក់នេះត្រូវបានអនុញ្ញាតឱ្យកាត់កងបន្ថែមនៅក្នុងឆ្នាំជាប់ពន្ធ។

៤- ប្រសិនបើនៅចុងបញ្ចប់នៃការបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ ចំណាយសរុបជាក់ស្តែងនៃការបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញមានចំនួនតិចជាងចំនួនសរុបនៃទឹកប្រាក់បម្រុងសម្រាប់ចំណាយបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញ ចំនួនលម្អៀងនោះត្រូវគិតបញ្ចូលក្នុងប្រាក់ចំណូលជាប់ពន្ធសម្រាប់ឆ្នាំជាប់ពន្ធដែលបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញនោះបានបញ្ចប់។

**ឧទាហរណ៍ទី៤៖** អ្នកជាប់ពន្ធ ក ធ្វើប្រតិបត្តិការប្រេងកាតក្នុងតំបន់ចុះកិច្ចព្រមព្រៀងមួយ ដែលមានអាយុកាលរំពឹងទុកនៃផលិតកម្មចំនួន ៥ឆ្នាំ។ ទឹកប្រាក់បម្រុងសម្រាប់បិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញដែលបានយល់ព្រមដោយស្ថាប័នមានចំនួន ៤០០ ០០០ រៀល។ ចំនួនទឹកប្រាក់បម្រុងសម្រាប់បិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញនេះ ត្រូវបានអនុញ្ញាតឱ្យកាត់កងចាប់ពីឆ្នាំជាប់ពន្ធទី១ រហូតដល់ឆ្នាំជាប់ពន្ធទី៥ ដោយក្នុងមួយឆ្នាំៗមានចំនួន ៨០ ០០០ រៀល។ នៅពេលការបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញត្រូវបានបញ្ចប់ អ្នកជាប់ពន្ធ ក បានចំណាយលើការបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញជាក់ស្តែងចំនួន ៣៥០ ០០០ រៀល ដែលតិចជាងទឹកប្រាក់បម្រុងចំនួន ៥០ ០០០ រៀល។ ទឹកប្រាក់លម្អៀងត្រូវគិតបញ្ចូលទៅក្នុងប្រាក់ចំណូលជាប់ពន្ធសម្រាប់ឆ្នាំជាប់ពន្ធដែលការបិទការដ្ឋាននិងស្តារបរិស្ថានឡើងវិញនោះបានបញ្ចប់។

**ប្រការ៧ .-**

វិធីរំលស់ ត្រូវបានកំណត់ដូចខាងក្រោម៖

១- អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ តាមវិធីរំលស់ស្មើភាគ តាមកថាខណ្ឌទី១ នៃមាត្រា១៣២ នៃច្បាប់ស្តីពីសារពើពន្ធ។ រំលស់ស្មើភាគ ត្រូវបានកំណត់ដូចខាងក្រោម៖

ក- អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយបុរេសនា និងចំណាយស្វែងរុករក តាមវិធីរំលស់ស្មើភាគតាមអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មក្រោមគម្រោងអភិវឌ្ឍន៍ ឬ ៥ឆ្នាំ ដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង។

ខ- អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយអភិវឌ្ឍន៍តាមវិធីរំលស់ស្មើភាគ តាមអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មរបស់មធ្យោបាយផលិតកម្មនីមួយៗក្រោមគម្រោងអភិវឌ្ឍន៍ ឬ ១០ឆ្នាំ សម្រាប់ប្រតិបត្តិការប្រេងកាត ដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង។

គ- ក្នុងករណីអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មរបស់មធ្យោបាយផលិតកម្មណាមួយក្រោមគម្រោងអភិវឌ្ឍន៍ត្រូវបានកែប្រែ អ្នកជាប់ពន្ធត្រូវកែតម្រូវការធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ដែលនៅសល់តាមអាយុកាលរំពឹងទុកដែលកែប្រែ ដោយមិនត្រូវលើសពីអាយុកាលរំលស់តាមវាក្យខណ្ឌ ក និងវាក្យខណ្ឌ ខ នៃកថាខណ្ឌនេះឡើយ។

ឃ-អាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មត្រូវកំណត់ដោយអ្នកជាប់ពន្ធដែលមានការយល់ព្រមពីស្ថាប័នដូចដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងប្រេងកាត។

**ឧទាហរណ៍ទី៥៖** អ្នកជាប់ពន្ធធ្វើប្រតិបត្តិការប្រេងកាតក្នុងតំបន់ចុះកិច្ចព្រមព្រៀងមួយ ដែលអាយុកាលរំពឹងទុកដំបូងនៃផលិតកម្មពាណិជ្ជកម្មមានរយៈពេល ៤ឆ្នាំ។ នៅដើមឆ្នាំទី៤ អ្នកជាប់ពន្ធបានសម្រេចចិត្តធ្វើការកែសម្រួលអាយុកាលរំពឹងទុកនៃមធ្យោបាយផលិតកម្មពាណិជ្ជកម្មរហូតដល់រយៈពេល ៥ឆ្នាំ។

| ចំណាយ | សរុប | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | ឆ្នាំទី៥ |
|---|---|---|---|---|---|---|
| ស្វែងរុករក | ១០០ | ២៥ | ២៥ | ២៥ | ១២,៥ | ១២,៥ |
| | ១០០% | ២៥% | ២៥% | ២៥% | ១២,៥% | ១២,៥% |
| អភិវឌ្ឍន៍ | ២០០ | ៥០ | ៥០ | ៥០ | ២៥ | ២៥ |
| | ១០០% | ២៥% | ២៥% | ២៥% | ១២,៥% | ១២,៥% |

**ឧទាហរណ៍ទី៦៖** អ្នកជាប់ពន្ធធ្វើប្រតិបត្តិការប្រេងកាតក្នុងតំបន់ចុះកិច្ចព្រមព្រៀងមួយ ដែលអាយុកាលរំពឹងទុកដំបូងនៃផលិតកម្មពាណិជ្ជកម្មមានរយៈពេល ៤ឆ្នាំ។ នៅដើមឆ្នាំទី៣ អ្នកជាប់ពន្ធបានសម្រេចចិត្តធ្វើការកែសម្រួលអាយុកាលរំពឹងទុកនៃមធ្យោបាយផលិតកម្មពាណិជ្ជកម្មថយចុះមកត្រឹម ៣ឆ្នាំ។

| ចំណាយ | សរុប | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | ឆ្នាំទី៥ |
|---|---|---|---|---|---|---|
| ស្វែងរុករក | ១០០ | ២៥ | ២៥ | ៥០ | 0 | 0 |
| | ១០០% | ២៥% | ២៥% | ៥០% | 0% | 0% |
| អភិវឌ្ឍន៍ | ២០០ | ៥០ | ៥០ | ១០០ | 0 | 0 |
| | ១០០% | ២៥% | ២៥% | ៥០% | 0% | 0% |

២-ចំពោះទ្រព្យរូបី ក្រៅពីចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ ដែលបានទិញឬបានបង្កើតក្រោយពេលចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មក្នុងតំបន់ចុះកិច្ចព្រមព្រៀង អ្នកជាប់ពន្ធត្រូវធ្វើរំលស់ទ្រព្យរូបីទាំងនោះ តាមវាក្យខណ្ឌ ក ដល់វាក្យខណ្ឌ ឃ នៃកថាខណ្ឌទី១ នៃមាត្រា១៣ នៃច្បាប់ស្តីពីសារពើពន្ធ។

៣-ចំពោះទ្រព្យអរូបី ក្រៅពីចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ អ្នកជាប់ពន្ធត្រូវធ្វើរំលស់តាមមាត្រា១៤ នៃច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ៨ .-**

ពេលធ្វើរំលស់ ត្រូវបានកំណត់ដូចខាងក្រោម ៖

១- អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ដែលបានកើតឡើងមុនពេលចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មដំបូងនៅដំណាច់ឆ្នាំជាប់ពន្ធ ដែលអ្នកជាប់ពន្ធចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មដំបូងក្នុងតំបន់ចុះកិច្ចព្រមព្រៀង។

២-ក្រោយពេលចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មដំបូងក្នុងតំបន់ចុះកិច្ចព្រមព្រៀង ប្រសិនបើអ្នកជាប់ពន្ធធ្វើបុរេសនា ឬស្វែងរុករក ឬសាងសង់បន្តនូវមធ្យោបាយផលិតកម្មដទៃទៀតក្រោមគម្រោងអភិវឌ្ឍន៍ក្នុងតំបន់ចុះកិច្ចព្រមព្រៀង អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ តាមពេលដូចខាងក្រោម៖

- ក- នៅដំណាច់ឆ្នាំជាប់ពន្ធនីមួយៗ ចំពោះចំណាយបុរេសនា ឬចំណាយស្វែងរុករក ទៅតាមលំដាប់ឆ្នាំដែលចំណាយនោះបានកើតឡើង។
- ខ- នៅដំណាច់ឆ្នាំជាប់ពន្ធដែលមធ្យោបាយផលិតកម្មនីមួយៗត្រូវបានដាក់ឱ្យប្រើប្រាស់ ចំពោះចំណាយអភិវឌ្ឍន៍។

៣-រំលស់ត្រូវធ្វើដាច់ដោយឡែកៗពីគ្នា សម្រាប់មធ្យោបាយផលិតកម្មនីមួយៗក្រោមគម្រោងអភិវឌ្ឍន៍ ស្របតាមកថាខណ្ឌទី១ នៃប្រការ៧ នៃប្រកាសនេះ ហើយត្រូវបូកសរុបបញ្ចូលគ្នាសម្រាប់កាត់កងក្នុងឆ្នាំជាប់ពន្ធ។

៤-ចំពោះទ្រព្យរូបី និងទ្រព្យអរូបី ក្រៅពីចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ដែលបានទិញ ឬបានបង្កើតក្រោយពេលចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មក្នុងតំបន់ចុះកិច្ចព្រមព្រៀង អ្នកជាប់ពន្ធត្រូវធ្វើរំលស់នៅដំណាច់ឆ្នាំជាប់ពន្ធដែលទ្រព្យទាំងនោះត្រូវបានដាក់ឱ្យប្រើប្រាស់។

៥-ប្រសិនបើប្រតិបត្តិការប្រេងកាតត្រូវបានបញ្ចប់ក្នុងឆ្នាំជាប់ពន្ធណាមួយ អ្នកជាប់ពន្ធត្រូវបានអនុញ្ញាតឱ្យកាត់កងជាចំណាយនូវតម្លៃទ្រព្យសកម្មដែលនៅសេសសល់ទាំងអស់ រួមបញ្ចូលទាំងចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ នៅក្នុងឆ្នាំជាប់ពន្ធ។

**ឧទាហរណ៍ទី៧៖** អ្នកជាប់ពន្ធធ្វើប្រតិបត្តិការប្រេងកាតនៅក្នុងតំបន់ចុះកិច្ចព្រមព្រៀងមួយ ដែលមានគ្រឿងបរិក្ខាររុករកប្រេងច្រើននៅក្នុងគម្រោងអភិវឌ្ឍន៍តែមួយដូចខាងក្រោម៖

- គម្រោងអភិវឌ្ឍន៍ដែលមានមធ្យោបាយផលិតកម្ម ៣ (ជើងទម្រសម្រាប់បូមប្រេងកាត) នឹងត្រូវសាងសង់ និងធ្វើប្រតិបត្តិការនៅតាមដំណាក់កាលនីមួយៗ

- អាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មនៃមធ្យោបាយផលិតកម្មទី១ គឺ ៦ឆ្នាំ និងមធ្យោបាយផលិតកម្មទី២ គឺ ៨ឆ្នាំ ហើយមធ្យោបាយផលិតកម្មទី៣ គឺ ៥ឆ្នាំ
- ផលិតកម្មពាណិជ្ជកម្មពីមធ្យោបាយផលិតកម្មទី១ ទី២ និងទី៣ នឹងចាប់ផ្តើមនៅឆ្នាំទី១ ឆ្នាំទី៦ និងឆ្នាំទី៩ រៀងគ្នា
- ចំណាយអភិវឌ្ឍន៍សរុប គឺ ៤៦០ ០០០ ០០០ រៀល រួមមាន (១) ២៤០ ០០០ ០០០ រៀល សម្រាប់មធ្យោបាយផលិតកម្មទី១ (២) ១៦០ ០០០ ០០០ រៀល សម្រាប់មធ្យោបាយផលិតកម្មទី២ និង (៣) ៦០ ០០០ ០០០ រៀល សម្រាប់មធ្យោបាយផលិតកម្មទី៣
- ចំណាយស្វែងរុករកសរុប គឺ ២៦០ ០០០ ០០០ រៀល រួមមាន (១) ១០០ ០០០ ០០០ រៀល សម្រាប់មធ្យោបាយផលិតកម្មទី១ ដែលបានបញ្ចប់នៅមុនឆ្នាំទី១ (២) ៥០ ០០០ ០០០ រៀល សម្រាប់ការរុករកដែលមិនបានសម្រេច ដែលបានធ្វើឡើងនៅក្នុងតំបន់គម្រោងអភិវឌ្ឍន៍ និងបានបញ្ចប់នៅក្នុងឆ្នាំទី២ (៣) ៨០ ០០០ ០០០ រៀល សម្រាប់មធ្យោបាយផលិតកម្មទី២ ដែលបានបញ្ចប់នៅក្នុងឆ្នាំទី៣ និង (៤) ៣០ ០០០ ០០០ រៀល សម្រាប់មធ្យោបាយផលិតកម្មទី៣ ដែលបានបញ្ចប់នៅឆ្នាំទី៧ និង
- គ្មានការពិនិត្យឡើងវិញទៅលើអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មនៃមធ្យោបាយផលិតកម្មណាមួយឡើយ។

| **ចំណាយ** | **រយៈពេលនៃការធ្វើរំលស់(ឆ្នាំ)** | **អាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្ម** | **សរុប (លាន)** | **ឆ្នាំ** | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | **១** | **២** | **៣** | **៤** | **៥** | **៦** | **៧** | **៨** | **៩** | **១០** | **១១** | **១២** | **១៣** | **១៤** |
| | ផលិតកម្មទី១ | | | | | | | | | | | | | | | | |
| ស្វែងរុករក | ៥ | ៦ | ១០០ | ២០ | ២០ | ២០ | ២០ | ២០ | – | – | – | – | – | – | – | – | – |
| អភិវឌ្ឍន៍ | ៦ | | ២៤០ | ៤០ | ៤០ | ៤០ | ៤០ | ៤០ | ៤០ | – | – | – | – | – | – | – | – |
| | ការរុករកមិនសម្រេច | | | | | | | | | | | | | | | | |
| ស្វែងរុករក | ៥ | | ៥០ | – | – | ១០ | ១០ | ១០ | ១០ | ១០ | – | – | – | – | – | – | – |
| អភិវឌ្ឍន៍ | ០ | | ០ | – | – | – | – | – | – | – | – | – | – | – | – | – | – |
| | ផលិតកម្មទី២ | | | | | | | | | | | | | | | | |
| ស្វែងរុករក | ៥ | ៨ | ៨០ | – | – | – | ១៦ | ១៦ | ១៦ | ១៦ | ១៦ | – | – | – | – | – | – |
| អភិវឌ្ឍន៍ | ៨ | | ១៦០ | – | – | – | – | – | ២០ | ២០ | ២០ | ២០ | ២០ | ២០ | ២០ | ២០ | – |
| | ផលិតកម្មទី៣ | | | | | | | | | | | | | | | | |
| ស្វែងរុករក | ៥ | ៥ | ៣០ | – | – | – | – | – | – | – | ៦ | ៦ | ៦ | ៦ | ៦ | – | – |
| អភិវឌ្ឍន៍ | ៥ | | ៦០ | – | – | – | – | – | – | – | – | ១២ | ១២ | ១២ | ១២ | ១២ | – |
| | សរុប | | | | | | | | | | | | | | | | |
| ស្វែងរុករក | | | ២៦០ | ២០ | ២០ | ៣០ | ៤៦ | ៤៦ | ២៦ | ២៦ | ២២ | ៦ | ៦ | ៦ | ៦ | – | – |
| អភិវឌ្ឍន៍ | | | ៤៦០ | ៤០ | ៤០ | ៤០ | ៤០ | ៤០ | ៦០ | ២០ | ២០ | ៣២ | ៣២ | ៣២ | ៣២ | ៣២ | – |
| **សរុប** | | | **៧២០** | **៦០** | **៦០** | **៧០** | **៨៦** | **៨៦** | **៨៦** | **៤៦** | **៤២** | **៣៨** | **៣៨** | **៣៨** | **៣៨** | **៣២** | – |

**ប្រការ៩ .-**

ក្នុងករណីមានការផ្ទេរមួយផ្នែកឬទាំងស្រុងនៃអត្ថប្រយោជន៍ដែលជាសិទ្ធិ ឬចំណែកក្នុងកិច្ចព្រមព្រៀងប្រេងកាត តាមរូបភាពលក់ទិញ ដោះដូរ ឬធ្វើអំណោយ អ្នកជាប់ពន្ធដែលជាអ្នកផ្ទេរ និងបុគ្គលជាអ្នកទទួលបន្ត ត្រូវអនុវត្តដូចខាងក្រោម៖

១- អ្នកជាប់ពន្ធដែលជាអ្នកផ្ទេរ ត្រូវកត់ត្រាចំណូលទទួលបានពីការផ្ទេរអត្ថប្រយោជន៍ក្នុងកិច្ចព្រមព្រៀងប្រេងកាត ជាចំណូលពីប្រតិបត្តិការប្រេងកាត ដែលជាកម្មវត្ថុនៃពន្ធលើប្រាក់ចំណូលស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធ។

២- បុគ្គលជាអ្នកទទួលបន្តត្រូវ៖

ក- បន្តអនុវត្តកាតព្វកិច្ចសារពើពន្ធពីអ្នកជាប់ពន្ធដែលជាអ្នកផ្ទេរ ចំពោះអត្ថប្រយោជន៍ដែលជាសិទ្ធិ ឬចំណែកដែលបានទទួល។

ខ- បន្តធ្វើរំលស់ទ្រព្យរូបី ទ្រព្យអរូបី ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ តាមវិធាន និងនីតិវិធី និងមូលដ្ឋានដែលអ្នកជាប់ពន្ធដែលជាអ្នកផ្ទេរបានធ្វើរំលស់កន្លងមក។

គ- ក្នុងករណីការផ្ទេរអត្ថប្រយោជន៍ក្នុងកិច្ចព្រមព្រៀងប្រេងកាត មានតម្លៃលើសពីតម្លៃពិតគណនេយ្យ តម្លៃលម្អៀងត្រូវបានចាត់ទុកជាមូលនិធិពាណិជ្ជកម្ម។ បុគ្គលជាអ្នកទទួលបន្ត ត្រូវធ្វើរំលស់មូលនិធិពាណិជ្ជកម្មនេះ តាមវិធីរំលស់ស្មើភាគតាមអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មដែលនៅសល់ ឬ ១០ឆ្នាំ ដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង។

ឃ-ក្នុងករណីការផ្ទេរអត្ថប្រយោជន៍ក្នុងកិច្ចព្រមព្រៀងប្រេងកាត មានតម្លៃតិចជាងតម្លៃពិតគណនេយ្យ តម្លៃលម្អៀងនោះត្រូវបានចាត់ទុកជាចំណូល។ បុគ្គលជាអ្នកទទួលបន្តត្រូវកត់ត្រាជាចំណូលសម្រាប់ឆ្នាំបន្តបន្ទាប់ដោយបែងចែកចំណូលទាំងនេះតាមសមាមាត្រនៃអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មដែលនៅសល់ ឬ ១០ឆ្នាំ ដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង។

**ប្រការ១០ .-**

១- ចំណាយដែលទាក់ទិននឹងប្រតិបត្តិការប្រេងកាតនៅក្នុងតំបន់ចុះកិច្ចព្រមព្រៀងណាមួយ សម្រាប់ឆ្នាំជាប់ពន្ធណាមួយ ត្រូវបានអនុញ្ញាតឱ្យកាត់កងតែពីប្រាក់ចំណូលដុលសរុបពីប្រតិបត្តិការប្រេងកាត ក្នុងតំបន់ចុះកិច្ចព្រមព្រៀងនៃឆ្នាំជាប់ពន្ធនោះប៉ុណ្ណោះ។

២- ចំណាយដែលទាក់ទិននឹងប្រតិបត្តិការប្រេងកាតនៅក្នុងតំបន់ចុះកិច្ចព្រមព្រៀងមួយ មិនអាចកាត់កងពីប្រាក់ចំណូលដុលសរុបពីប្រតិបត្តិការប្រេងកាតនៅក្នុងតំបន់ចុះកិច្ចព្រមព្រៀងដទៃទៀតទេ ហើយក៏មិនអាចកាត់កងពីប្រាក់ចំណូលដុលសរុបពីប្រភពផ្សេងទៀតក្រៅពីប្រតិបត្តិការប្រេងកាតឡើយ។

**ប្រការ១១ .-**

១- ប្រសិនបើនៅក្នុងឆ្នាំជាប់ពន្ធណាមួយ ចំណាយសរុបដែលទាក់ទិននឹងប្រតិបត្តិការប្រេងកាតនៅក្នុងតំបន់ចុះកិច្ចព្រមព្រៀង លើសពីចំណូលដុលសរុបដែលនាំឱ្យមានលទ្ធផលខាតបង់ ការខាតបង់ត្រូវបានអនុញ្ញាតឱ្យយោងទៅកាត់កងពីប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានក្នុងឆ្នាំជាប់ពន្ធបន្ទាប់។

២- ប្រសិនបើប្រាក់ចំណូលជាប់ពន្ធ នៃឆ្នាំជាប់ពន្ធបន្ទាប់មិនគ្រប់គ្រាន់សម្រាប់កាត់កងការយោងខាតជាស្ថាពរទេ ចំណែកនៃការខាតបង់ដែលនៅសេសសល់ត្រូវបានអនុញ្ញាតឱ្យយោងទៅមុខរហូតដល់ ១០ឆ្នាំ ដោយមិនគិតថាអ្នកជាប់ពន្ធមានប្រាក់ចំណូលជាប់ពន្ធ ឬខាតបង់នោះទេ។ ប្រសិនបើក្នុងរយៈពេល ១០ឆ្នាំ ចំណែកនៃការយោងការខាតបង់មិនអាចកាត់កងអស់ជាស្ថាពរទេ ចំណែកខាតបង់ដែលនៅសេសសល់នោះមិនត្រូវបានអនុញ្ញាតឱ្យកាត់កងទៀតឡើយ។ ក្នុងករណីដែលមានការខាតបង់លើសពីមួយឆ្នាំ ការយោងការខាតបង់ត្រូវអនុវត្តតាមលំដាប់ឆ្នាំដែលការខាតបង់ទាំងឡាយបានកើតឡើង។

៣- ការខាតបង់ដែលកើតមានឡើងនៅក្នុងតំបន់ចុះកិច្ចព្រមព្រៀងមួយមិនអាចយោងយកទៅកាត់កងក្នុងតំបន់ចុះកិច្ចព្រមព្រៀងដទៃទៀតឡើយ។



h

៣-ការខាតបង់ដែលកើតមានឡើងនៅក្នុងតំបន់ចុះកិច្ចព្រមព្រៀងមួយមិនអាចយោងយកទៅកាត់កងក្នុងតំបន់ចុះកិច្ចព្រមព្រៀងដទៃទៀតឡើយ។

**ឧទាហរណ៍ទី៨៖**

- ក្នុងឆ្នាំជាប់ពន្ធទី១ អ្នកជាប់ពន្ធ ក មានលទ្ធផលខាត ចំនួន ១០០ ០០០ រៀល
- ក្នុងឆ្នាំជាប់ពន្ធទី២ មានលទ្ធផលខាត ចំនួន ៦០ ០០០ រៀល
- ក្នុងឆ្នាំជាប់ពន្ធទី៣ អ្នកជាប់ពន្ធ ក មានប្រាក់ចំណូលសុទ្ធ (ចំណេញ) ចំនួន ៧០ ០០០ រៀល។ អ្នកជាប់ពន្ធ ក អាចប្រើប្រាស់ទឹកប្រាក់ ៧០ ០០០ រៀល នេះ ដើម្បីកាត់កងការខាតបង់ដែលបានកើតឡើងក្នុងឆ្នាំជាប់ពន្ធទី១ ចំនួន ១០០ ០០០ រៀល។ ដូចនេះ អ្នកជាប់ពន្ធ ក នៅសល់ការខាតបង់ក្នុងឆ្នាំទី១ ចំនួន ៣០ ០០០ រៀល និង ការខាតបង់ក្នុងឆ្នាំទី២ ចំនួន ៦០ ០០០ រៀល
- ក្នុងឆ្នាំជាប់ពន្ធទី៤ អ្នកជាប់ពន្ធ ក មានប្រាក់ចំណូលសុទ្ធ (ចំណេញ) ចំនួន ៨០ ០០០ រៀល ។ អ្នកជាប់ពន្ធ ក អាចប្រើប្រាស់ទឹកប្រាក់ ៨០ ០០០ រៀល នេះ ដើម្បីកាត់កងការខាតបង់ដែលបានកើតឡើងក្នុងឆ្នាំជាប់ពន្ធទី១ ចំនួន ៣០ ០០០ រៀល និង ៥០ ០០០ រៀល ទៀត សម្រាប់កាត់កងការខាតបង់ ៦០ ០០០រៀល ក្នុងឆ្នាំជាប់ពន្ធទី២។ អ្នកជាប់ពន្ធ ក នៅសល់ការខាតបង់ក្នុងឆ្នាំជាប់ពន្ធទី២ ចំនួន ១០ ០០០ រៀល ដើម្បីយោងទៅឆ្នាំជាប់ពន្ធទី៥ និងឆ្នាំជាប់ពន្ធបន្តបន្ទាប់ ប៉ុន្តែមិនលើសចំនួន ១០ឆ្នាំជាប់ពន្ធ ចាប់ពីឆ្នាំជាប់ពន្ធទី២ ឡើយ។

**ប្រការ១២ .-**

១- អ្នកជាប់ពន្ធមានកាតព្វកិច្ចបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលប្រចាំខែតាមអត្រា ១ (មួយ) ភាគរយ នៃផលរបរដែលសម្រេចបានក្នុងខែមុន ដោយគិតរួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម។ ប្រាក់រំដោះពន្ធលើប្រាក់ចំណូលនឹងត្រូវបានយកមកកាត់កងពីពន្ធលើប្រាក់ចំណូលនៅពេលធ្វើការទូទាត់ប្រចាំឆ្នាំ។

២- នៅពេលដាក់លិខិតប្រកាសបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ប្រសិនបើប្រាក់រំដោះពន្ធលើប្រាក់ចំណូលដែលបានបង់ក្នុងឆ្នាំជាប់ពន្ធណាមួយ ច្រើនជាងបំណុលពន្ធលើប្រាក់ចំណូល ចំនួនលម្អៀងត្រូវបានអនុញ្ញាតជាឥណទានសម្រាប់ប្រើប្រាស់ជាប្រាក់រំដោះពន្ធលើប្រាក់ចំណូលសម្រាប់ខែបន្តបន្ទាប់ ក្រោយពីការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំជាប់ពន្ធនោះ។

៣-នៅពេលបញ្ចប់ប្រតិបត្តិការប្រេងកាត ប្រសិនបើមាននៅសល់ឥណទានប្រាក់រំដោះពន្ធលើប្រាក់ចំណូល អ្នកជាប់ពន្ធអាចធ្វើការស្នើសុំទៅរដ្ឋបាលសារពើពន្ធ ឱ្យបង្វិលសងនូវឥណទានប្រាក់រំដោះពន្ធលើប្រាក់ចំណូលដែលនៅសល់នោះ។

**ប្រការ១៣ .-**

១- អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាសសារពើពន្ធនិងបង់ប្រាក់ពន្ធអាករប្រចាំខែ ប្រចាំឆ្នាំ ដាច់ដោយឡែកពីគ្នាជូនរដ្ឋបាលសារពើពន្ធ ទៅតាមការកំណត់នៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ។

២- ប្រតិបត្តិករដែលជាតំណាងអ្នកជាប់ពន្ធទាំងអស់ក្នុងតំបន់ចុះកិច្ចព្រមព្រៀង ត្រូវផ្តល់របាយការណ៍និងឯកសារនានានៃប្រតិបត្តិការអាជីវកម្មក្នុងតំបន់ចុះកិច្ចព្រមព្រៀង តាមការតម្រូវរបស់រដ្ឋបាលសារពើពន្ធ។

**ប្រការ១៤ .-**

អ្នកជាប់ពន្ធអាចស្នើសុំការអនុញ្ញាតពីរដ្ឋបាលសារពើពន្ធ ដើម្បីប្រើប្រាស់ភាសាអង់គ្លេស និងប្រើប្រាស់រូបិយប័ណ្ណជាប្រាក់ដុល្លារអាមេរិក សម្រាប់កត់ត្រាបញ្ជិកាគណនេយ្យ របាយការណ៍ និងឯកសារនានាដែលទាក់ទិននឹងប្រតិបត្តិការប្រេងកាត។



ℎ

**ប្រការ១៦ .-**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហ.១១កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី-ខេត្ត
- ដូចប្រការ១៦ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ